UNITED NATIONS
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

# PRESS RELEASE

## ជនជាតិដើមភាគតិចបីសហគមន៍នឹងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព

សហគមន៍ជនជាតិដើមភាគតិចចំនួនបីភូមិ ដែលមានប្រជាពលរដ្ឋ ៣២៩ គ្រួសារ នៅតំបន់ភាគឦសាន្តនៃប្រទេសកម្ពុជា ត្រូវបានរាជរដ្ឋាភិបាលផ្តល់ជូនប័ណ្ណកម្មសិទ្ធិដីសមូហភាព លើកដំបូងដែលបានផ្តល់ឲ្យនៅក្នុងប្រទេសនេះ។

នៅក្នុងពិធីបុណ្យរួមគ្នាមួយ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១១ នៅខេត្តរតនគីរី សមាជិកសហគមន៍ភូមិឡាអិន ក្នុងឃុំតឺន ស្រុកកូនមុំ និងភូមិល្អឺនក្រែន ក្នុងឃុំ អូជុំ ស្រុក អូជុំ បានទទួលប័ណ្ណកម្មសិទ្ធិដីសមូហភាពលើផ្ទៃដី ១.៤៥៤ ហិកតា និង ៩២០ ហិកតា រៀងៗខ្លួន។

សហគមន៍ទីបីដែលនឹងទទួលបាន គឺសហគមន៍អណ្តូងក្រឡឹង ក្នុងឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគីរីនឹងទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពទំហំ១.៤២៥ ហិកតាក្នុងខែមករា ឆ្នាំ២០១២ខាងមុខ។

សហគមន៍បីនេះតំណាងឲ្យជនជាតិដើមភាគតិចផ្សេងៗគ្នាគឺ ភូមិឡាអិនដែលមានជនជាតិដើមភាគតិចគ្រឹងនិងទំពួនរស់នៅ ចំណែកឯ ភូមិល្អឺនក្រែន វិញ ភាគច្រើនជាជនជាតិដើមភាគតិចទំពួនរស់នៅ។ នៅភូមិអណ្តូងក្រឡឹង មានសុទ្ធតែជនជាតិដើមភាគតិចព្នងរស់នៅ។

ប័ណ្ណកម្មសិទ្ធិដីសមូហភាពសំរាប់ជនជាតិដើមភាគតិច ត្រូវបានក្រសួងពាក់ព័ន្ធអនុម័តកាលពីចុងឆ្នាំនេះ បន្ទាប់ពីដាក់ឲ្យសាកល្បងសហគមន៍ចំនួនបី បានដាក់ពាក្យសុំរបស់ខ្លួនក្នុងឆ្នាំ២០០៩។ សិទ្ធិទទួលបានកម្មសិទ្ធិដីសមូហភាពសំរាប់ជនជាតិដើមភាគតិច មានចែងក្នុងច្បាប់ភូមិបាលឆ្នាំ ២០០១ និងក្នុងឯកសារគោលនយោបាយ និងបទដ្ឋានគតិយុត្តបន្តបន្ទាប់មកទៀត។ រាជរដ្ឋាភិបាល កម្ពុជាបានសំដែងផងដែរអំពីការសន្យារបស់ខ្លួននៅឆាកអន្តរជាតិចំពោះសិទ្ធិដីធ្លីរបស់ជនជាតិដើម ភាគតិច



No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

United Nations Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia

នៅពេលដែលកម្ពុជាបានបោះឆ្នោតគាំទ្រការអនុម័តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ក្នុងឆ្នាំ២០០៧។

"ការយល់ព្រមផ្តល់ប័ណ្ណកម្មសិទ្ធិដីសហាម្ហូហាភាពនេះ គឺជាសមិទ្ធិផលដ៏ធំមួយ និងបង្ហាញឲ្យ ឃើញពីការដែលរដ្ឋាភិបាលគោរពសិទ្ធិជនជាតិដើមភាគតិច និងទទួលស្គាល់ ការរួមវិភាគទានដ៏ សំខាន់របស់ជនជាតិដើមភាគតិចក្នុងការអភិវឌ្ឍន៍ជាតិ" នេះបើតាមប្រសាសន៍របស់ការិយាល័យ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា(ការិយាល័យ OHCHR) ។ ការិយាល័យ OHCHR ស្ញើចសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរួមរបស់ក្រសួងសំខាន់ៗ អាជ្ញាធរ ខេត្ត/ក្រុង អង្គការពលកម្មអន្តរជាតិ(អង្គការ ILO)   និងអង្គការមិនមែនរដ្ឋាភិបាល(NGOs)នានា ដែលគាំ ទ្រដល់សហគមន៍ជនជាតិដើមភាគតិចនៅទូទាំងដំណើរដាក់ពាក្យសុំទាំងមូល ។

"គំនិតផ្តួចផ្តើមនេះ គឺជាកំលាំងជំរុញ(ចលករ) មួយសំរាប់សហគមន៍ជនជាតិដើមភាគតិចដទៃទៀតនៅទូទាំងប្រទេស ដើម្បីអះអាងជាថ្មីអំពីបូរណភាពវប្បធម៌របស់ខ្លួន និងចាត់វិធានការឈានទៅរក្សាការពារធនធាន និង ដីកេរ្តិ៍ដូនតារបស់ខ្លួន... ដែលពិតណាស់ មានសហគមន៍មួយចំនួនទៀតកំពុងស្ថិតនៅលើដំណើរផ្លូវនេះរួចហើយ" ការិយាល័យ OHCHR បានបញ្ជាក់បន្ថែមដូច្នេះ។ "ការផ្តល់ប័ណ្ណកម្មសិទ្ធិដីសម្ហូហាភាពនេះ តំណាងឲ្យការការពារដ៏សំខាន់មួយប្រឆាំងនឹងការដកហូតសិទ្ធិលើដីធ្លី ដូចមានចែងក្នុងសេចក្តីប្រកាសរបស់ អ.ស.ប ស្តីពីសិទ្ធិជនជាតិដើមភាគតិច។" *

នៅពេញមួយឆ្នាំ ការិយាល័យ OHCHR ប្រចាំកម្ពុជា បាននិងកំពុងជួយដល់ជនជាតិដើមភាគតិចព្នងចំនួនប្រាំពីរសហគមន៍ ក្នុងឃុំប៊ូស្រា ស្រុកពេជ្រាដា ខេត្តមណ្ឌលគីរី ដើម្បីចុះបញ្ជីជានីតិ បុគ្គល។ ពាក្យសុំប័ណ្ណកម្មសិទ្ធិដីសម្ហូហាភាពរបស់សហគមន៍ទាំងប្រាំពីរនេះទំនងជាធ្វើនៅក្នុង ឆ្នាំ ២០១២ ខាងមុខនេះ។

** មាត្រា៨ (២) (ខ) និងមាត្រា ១០, ២៥, ២៦, ២៧, ២៨, ២៩, ៣០ និង មាត្រា៣២ នៃសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច បរិយាយអំពីសិទ្ធិជាក់លាក់របស់ជនជាតិដើមភាគតិច ក្នុងការមានដីប្រពៃណីរបស់ខ្លួន។*

*សំរាប់អត្ថបទទាំងស្រុងនៃសេចក្តីប្រកាសរបស់ អ.ស.ប នេះ សូមចូលទៅកាន់វិបសាយ ៖*
*http://www2.ohchr.org/english/issues/indigenous/declaration.htm*

*សំរាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកញ្ញា ហ្ស៊ូអ៊ី ឡាធំបូ (ទូរស័ព្ទលេខ +៨៥៥ ០១២ ៧៩០ ១៧៨ /អ៊ីម៉េល* zlatumbo@ohchr.org *) លោក អៀន ករុណា (ទូរស័ព្ទលេខ +៨៥៥ ០១២ ៥៦៣ ៨៥៨ /អ៊ីម៉េល* kean@ohchr.org *) លោក សេក សោភ័ណ្ឌ (ទូរស័ព្ទលេខ +៨៥៥ ០១២ ៨៩០ ២៨៩ /អ៊ីម៉េល* sophorns@ilo.org*)*

End.

The Office of the High Commissioner for Human Rights (OHCHR) is the principal United Nations agency responsible for the promotion and protection of human rights. OHCHR has been operating in Cambodia since 1993.

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342  Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org  Website: http://cambodia.ohchr.org

United Nations Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS
Cambodia Country Office - Phnom Penh - Cambodia